# រឿង កុមារមេត្តា



# រឿង កុមារមេត្តា

និពន្ធដោយ លោក គាំ សារ៉ែន
គូររូបដោយ លោក គាំ សារ៉ែន

រក្សាសិទ្ធិដោយ អង្គការសន្តិស្ម័គ្រចិត្ត (SVA)

បោះពុម្ពឆ្នាំ២០០៦

# រឿង កុមារមេត្តា



បោះពុម្ពផ្សាយដោយអង្គការសន្តិស្ម័គ្រចិត្ត (SVA)
និពន្ធ និងគូររូបភាពដោយ លោក គាំ សារ៉ែន



មានរឿងមួយតំណាលថា នៅជនបទដាច់ស្រយាលមានបុរសពោះម៉ាយមានកូនពីរនាក់ ។ កូនបងឈ្មោះ ចំរុង ឯកូនប្អូនឈ្មោះ មេត្តា ។ គ្រួសារនេះរស់នៅក្នុងភាពក្រីក្រលំបាកពន់ពេក គ្មានគោ ក្របី ដីស្រែនឹងគេ ។ ឯកូនទាំងពីរក៏កាន់តែធំ ។ ដោយរស់នៅក្នុងក្តីតោកយ៉ាក គាត់មានភាពអាម៉ាស់នឹងអ្នកស្រុកភូមិ គាត់ក៏សំរេចចិត្តនាំកូនទាំងពីរចេញពីភូមិកំណើតស្វែងរកកន្លែងរស់នៅថ្មី ។





ក្រោយពេលចាកចេញពីផ្ទះ ហើយធ្វើដំណើរជាច្រើនថ្ងៃ គាត់ និងកូនទាំងពីរបានមកដល់ព្រៃមួយ ដែលមានរុក្ខជាតិពណ៌បៃតង មានត្រពាំង បឹង និងសត្វតូចធំយ៉ាងច្រើន ។ ទាំងអស់នេះបានធ្វើអោយអារម្មណ៍គាត់រំភើប ហើយគាត់គិតថា នឹងរៀបចំកសាងជីវិតថ្មីអោយបានប្រសើរឡើង ។ គាត់ និងកូនទាំងពីរបានចាប់ផ្តើមសាងសង់ផ្ទះនៅទីនោះ ។ ពេលនោះ ពពួកសត្វទាំងឡាយ ក៏តាមមើលសកម្មភាពរបស់ឪពុក និងកូនទាំងពីរនាក់ ។ តើពួកគេមកជាមិត្ត ឬសត្រូវ ? ។





នៅពេលដែល ឪពុក និងកូនបងកំពុងរៀបចំសង់ផ្ទះ មេត្តាតែងដើរតាមមើលពួកសត្វទាំងឡាយ ។ គេព្យាយាមចងមិត្តភាពជាមួយពួកសត្វដែលជាម្ចាស់ដីដោយក្ដីស្រលាញ់អស់ពីដួងចិត្ត ។ មេត្តានិយាយទៅសត្វទាំងនោះ ថា " ខ្ញុំជាអ្នកថ្មី ! ខ្ញុំរីករាយ និងពេញចិត្តណាស់ចំពោះការយល់អធ្យាស្រ័យអោយគ្រួសារខ្ញុំរស់លើទឹកដីដ៏ស្រស់ស្អាតនេះ " ។



ប៉ុន្តែ ជាអកុសលប៉ុន្មានថ្ងៃក្រោយមក បន្ទាប់ពីរៀបចំផ្ទះសំបែងរួច ឪពុក និងបងរបស់មេត្តាបាននាំគ្នាទៅបរបាញ់សត្វដើម្បីយកទៅលក់ដូរនៅទីផ្សារ ។ គាត់គ្មានអាសូរសត្វទាំងនោះបន្តិចណាសោះ គឺធ្វើយ៉ាងណាអោយតែខ្លួនឯងបានរស់ ។ ក្នុងមួយថ្ងៃៗ គាត់ចេញទៅបរបាញ់សត្វបានបីទៅបួនក្បាល ទើបត្រលប់មកផ្ទះ ។



មេត្តាក្តុកក្តួលចិត្តយ៉ាងខ្លាំង នៅពេលដែលបានឃើញឪពុក និងបងប្រុសរបស់ខ្លួនប្រព្រឹត្តអំពើមិនគប្បីដែលផ្ទុយនឹងឆន្ទៈរបស់គេ ។ មេត្តាចង់រស់នៅជាគ្រួសារធំដោយសុខសាន្តជាមួយពួកសត្វជាមិត្តដ៏ល្អបំផុតតែប៉ុណ្ណោះ ។ គេមានការសោកស្តាយ ចំពោះអ្វីៗ ដែលកើតឡើងនៅពេលនេះ ។

ពេលសម្រាក ក្រោយបរិភោគអាហារពេលល្ងាចរួច មេត្តាបានព្យាយាមអង្វរឪពុកអោយឈប់សំលាប់សត្វទាំងនោះទៀត ។ គេចង់អោយឪពុករកជីវភាពក្បែរនោះ ហើយកាប់គាស់ ដាំស្រូវ និងដាំដំណាំវិញ ប៉ុន្តែ គ្មានប្រយោជន៍ទេ ព្រោះមេត្តាបានត្រឹមទទួលការស្តីបន្ទោសយ៉ាងច្រើនពីឪពុកទៅវិញ ។

ថ្ងៃ ខែ ឆ្នាំ បានកន្លងផុតទៅជាបន្តបន្ទាប់ ។ សត្វគ្រប់ប្រភេទបាត់បង់កាន់តែច្រើន ។ ដោយទ្រាំនឹងការសំលាប់រង្គាលទៀតពុំបាន យប់មួយ ពពួកសត្វដែលនៅសេសសល់បាននាំគ្នាភៀសខ្លួនស្វែងរកកន្លែងសុខសាន្តមួយផ្សេងទៀត ។



ព្រឹកឡើង មេត្តាហាក់ដូចជាចំលែកចិត្តយ៉ាងខ្លាំង ។ គេរត់ចូលព្រៃសំលឹងតាមរកមិត្តរបស់គេ ដោយបញ្ចេញសំលេងស្រែកហៅរកមិត្តផ្អូនៗ តែពុំប្រទះសត្វណាមួយឡើយ ។ ទីបំផុត គេបានឃើញស្នាមដានជើងសត្វដែលភៀសខ្លួនចេញពីយប់មិញ ។ គេភ្ញាក់អារម្មណ៍ ហើយពោលតិចៗថា "សូមមិត្តទៅអោយបានសុខចុះ ថ្ងៃណាមួយយើងនឹងជួបគ្នាវិញ" ។





ឪពុកមេត្តា មិនគិតគូរអ្វីឡើយ ។ គាត់ហ៊ានធ្វើអ្វីៗទាំងអស់អោយតែទទួលបានផលកំរៃ ។ ក្រោយពីគ្មានសត្វបរបាញ់ គាត់ចាប់ផ្តើមកាប់ដើមឈើវិញម្តង ហើយអាចរកប្រាក់បានដូចលក់សត្វដែរ ។ មេត្តាអង្វរឪពុកម្តងទៀតថា « សូមលោកឪពុកបញ្ឈប់ទៅ ព្រោះវានាំអោយវិនាសខ្លួនឯងនៅថ្ងៃមុខ » ។ ប៉ុន្តែ គាត់នៅតែមានះធ្វើបន្តទៀត ។

ច្រើនឆ្នាំកន្លងផុតទៅ ព្រៃឈើនេះក៏ត្រូវរេចរឹលទៀត ។ អាកាសធាតុក្តៅ ត្រពាំងបឹងបួរឹងហួតអស់ ។ ឯសម្បត្តិធម្មជាតិជុំវិញខ្លួនក៏វិនាសហិនហោចទៀត ដោយអស់សង្ឃឹម ហើយវ័យកាន់តែចាស់ គាត់ក៏ធ្លាក់ខ្លួនឈឺជាទំងន់ ។ ពេលនេះទើបគាត់នឹកឃើញសំដីរបស់មេត្តា ។ ប៉ុន្តែ អ្វីៗ ហួសអស់ ។ មុននឹងស្លាប់ គាត់ផ្តាំប្រាប់កូនទាំងពីរអោយស្តាប់យោបល់គ្នា ពិសេស ត្រូវស្តាប់តាមមេត្តា តើគួរធ្វើអ្វីតទៅទៀត ។







ក្រោយពេលបញ្ចុះសពឪពុករួច មេត្តានិយាយទៅកាន់ចំរុងជាបងថា « បង! យើងត្រូវតែចេញពីទីនេះ រួចធ្វើអ្វីៗទាំងអស់ដើម្បីអោយទីនេះស្រស់បំព្រងឡើងវិញ ។ យើងត្រូវទុកអោយធម្មជាតិល្អស្រស់ដូចពីមុន មានដើមឈើ វាលស្មៅ ផ្ការីក មានទឹកក្នុងត្រពាំង បឹង និងសត្វមានជីវិតជាច្រើនទៀត ។ តែយើងត្រូវខំដាំស្រូវ បន្លែ ផ្លែឈើដែលជាស្បៀងចាំបាច់របស់យើង » ។ ថាហើយ គេនាំបងដើរតាមស្នាមចង្កូរដានជើងសត្វភៀសខ្លួន ។ ទីបំផុតក៏មកដល់ព្រៃមួយមានសណ្ឋានដូចព្រៃដែលគ្រួសារគេបានជួបកាលពីមុន ។





ពេលបានឃើញព្រៃដែលជាសម្បត្តិធម្មជាតិស្រស់ត្រកាល មេត្តារីករាយណាស់ ។ គេញញឹមដាក់បង ហើយនិយាយថា ״យើងមកដល់ទីនេះតាមចង្អូរជានជើងសត្វ ។ យើងត្រូវកាយទឹកទំលាក់តាមចង្អូរនោះ វាពិតជានាំទឹកចូលត្រពាំងបឹងនៅភូមិព្រៃចាស់យើងមិនខាន» ។



កុមារទាំងពីរជញ្ជូនកូនឈើតូចៗ គ្រប់ប្រភេទយកទៅដាំជាបន្តបន្ទាប់នៅព្រៃដែលរេចរឹល ។ អាស្រ័យដោយមានប្រភពទឹកដែលហូរពីតំបន់ព្រៃថ្មី តាមស្នាមចង្អូរដានជើងសត្វ ធ្វើអោយត្រពាំង បឹងមានទឹកគ្រប់គ្រាន់ ។ ភូមិព្រៃចាស់ដែលរេចរឹល និងហួតហែងក្លាយជាទីស្រស់បំព្រងវិញ ។ ឯសួនបន្លែក៏លូតលាស់បានផលល្អសំរាប់ធ្វើស្បៀងជាប្រចាំ ។ ពួកគេមានអារម្មណ៍ភ្លឺថ្លា ។ មេត្តាសង្ឃឹមក្នុងចិត្តថា « ពេលដែលកូនឈើដុះលូតលាស់ធំអាចជាជំរកសត្វបាន នោះមិត្តរបស់គេទាំងអស់នឹងត្រលប់មកវិញមិនខាន » ។





ច្រើនខែ ឆ្នាំកន្លងទៅ រុក្ខជាតិទាំងឡាយដុះធំល្អ ។ ព្រឹកមួយនោះ មានសំលេងសត្វលាន់រំពង ។ មេត្តា និងចំរុងស្ទុះទៅរកសំលេងនោះ ។ គេរំភើបចិត្តណាស់ ព្រោះលើវាលស្មៅនៅពីមុខគេ ហ្វូងសត្វយ៉ាងច្រើនឈរត្រៀបត្រាសំលឹងមើលមក ដោយទឹកមុខស្រស់ស្រាយ ។ មេត្តានិយាយខ្លាំងៗ ថា « ស្វាគមន៍! ចំពោះវត្តមានជាថ្មីលើដីព្រៃចាស់របស់មិត្តទាំងអស់ ។ ខ្ញុំសូមអះអាងថា អំណឹះតទៅកន្លែងនេះ មានតែភាពសំបូររុងរឿង និងសុខសាន្ត គ្មានការកាប់សំលាប់ ឬបំផ្លាញទៀតទេ ។ យើងត្រូវការសន្តិភាព ជយោ! សន្តិភាព » ៕

ចប់

754964